**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ: ០៩០/ក្រ.ក ២០១១

រាជធានីភ្នំពេញ, ថ្ងៃទី...០៦...ខែ...ធ្នូ...ឆ្នាំ២០១១...

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
អគ្គលេខាធិការដ្ឋាន
ចូល លេខ...252...
ថ្ងៃទី...21.12.2011 ម៉ោង 10.10
បញ្ជូន...

# ប្រកាស

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមការងារដើម្បីកុមារ នៃកងយោធពលខេមរភូមិន្ទ

## រដ្ឋមន្ត្រីក្រសួងការពារជាតិ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ០២ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

-បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានចុះហត្ថលេខានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២

-បានឃើញសេចក្តីសម្រេចលេខ១២៧ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ស្តីពីការបង្កើតក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន

-យោងតាមតម្រូវការចាំបាច់នៃការអភិវឌ្ឍន៍សុខុមាលភាពកុមារ



05 DEC 2011

## សម្រេច

**ប្រការ១**: ត្រូវបានតែងតាំងសមាសភាពក្រុមការងារដើម្បីកុមារនៃកងយោធពលខេមរភូមិន្ទ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-នាយឧត្តមសេនីយ៍ | **នាង ផាត** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ប្រធាន |
| ២-ឧត្តមសេនីយ៍ឯក | **នាង អេង** | អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និងជានាយក នាយកដ្ឋានអប់រំ | អនុប្រធាន |
| ៣-ឧត្តមសេនីយ៍ឯក | **លី ដេត** | អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ - ហិរញ្ញវត្ថុ | សមាជិក |
| ៤-ឧត្តមសេនីយ៍ឯក | **ប៉ាង ឆារ៉ូ** | អគ្គលេខាធិការរង ក្រសួងការពារជាតិនិងជានាយកនាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ៥-ឧត្តមសេនីយ៍ឯក | **គង់ សាលី** | អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ និងជានាយក នាយកដ្ឋានសុខាភិបាល | សមាជិក |
| ៦-ឧត្តមសេនីយ៍ទោ | **ជួប សំបូរ** | នាយករង នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧-ឧត្តមសេនីយ៍ទោ | **ម៉ី មនដារី** | នាយករង នាយកដ្ឋានកិច្ចការយោធាស៊ីវិល | សមាជិក |
| ៨-ឧត្តមសេនីយ៍ទោ | **វណ្ណា ហ៊ីច** | នាយករង នាយកដ្ឋាននីតិកម្ម | សមាជិក |
| ៩-ឧត្តមសេនីយ៍ត្រី | **ឃុន ហ៊ីន** | នាយករងទីចាត់ការឃោសនាពត៌មាន | សមាជិក |

**ប្រការ២**: ក្រុមការងារដើម្បីកុមារនៃកងយោធពលខេមរភូមិន្ទ មានតួនាទីនិងភារកិច្ច៖

-ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងបញ្ហាកុមារជាកូនចៅយោធិននៅក្នុងកងយោធពលខេមរភូមិន្ទ

-ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនិងលើកសំណើជូនគណៈកម្មាធិការជាតិកម្ពុជាដើម្បីកុមារ "**គ.ជ.ក**" ពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារនិងបំផុសចលនាគាំទ្រការអនុវត្តន៍សិទ្ធិកុមារឱ្យមានប្រសិទ្ធភាព

-រៀបចំផែនការ កម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍កុមារ សម្រាប់កងយោធពលខេមរភូមិន្ទមានជាអាទិ៍: ការគោរពនិងការអនុវត្តន៍សិទ្ធិកុមារ ការរស់រានមានជីវិត ការអភិវឌ្ឍន៍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហឹង្សា ការទប់ស្កាត់ ការលុបបំបាត់ការកេងប្រវ័ញ្ចន៍គ្រប់រូបភាពមកលើកុមារនិងប្រឆាំងនឹងការជួញដូរគ្រឿងញៀន

-បញ្ជ្រាបការងារកុមារទៅក្នុងកម្មវិធីការងាររបស់កងយោធពលខេមរភូមិន្ទ

-ធ្វើទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារជាកូនចៅយោធិននៅក្នុងកងយោធពលខេមរភូមិន្ទ ដើម្បីរកជំនួយឧបត្ថម្ភនិងផ្លាស់ប្តូរពត៌មាន បទពិសោធន៍ ទស្សនៈរីកចម្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារជាកូនចៅយោធិននៅក្នុងកងយោធពលខេមរភូមិន្ទ

-រៀបចំមូលដ្ឋានទិន្នន័យ ស្តីពីស្ថានភាពកុមារជាកូនចៅយោធិននៅក្នុងកងយោធពលខេមរភូមិន្ទ

-រៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា

-ចាត់ចែងអនុវត្តរាល់គោលការណ៍ ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ "**ក.ជ.ក**"

-អនុវត្តភារកិច្ចផ្សេងៗទៀតដែល **ក.ជ.ក** ប្រគល់ជូន។

**ប្រការ៣**: ក្រុមការងារដើម្បីកុមារនៃកងយោធពលខេមរភូមិន្ទ ត្រូវជួបប្រជុំយ៉ាងតិច២ (ពីរ)ដងក្នុងមួយឆ្នាំ ។ ក្នុងករណីចាំបាច់ ក្រុមការងារដើម្បីកុមារនៃកងយោធពលខេមរភូមិន្ទ អាចប្រជុំជាវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន។ ក្រុមការងារដើម្បីកុមារនៃកងយោធពលខេមរភូមិន្ទ ត្រូវធ្វើការបូកសរុបរបាយការណ៍ អំពីលទ្ធផលនៃការអនុវត្តន៍សកម្មភាពការងារ រៀងរាល់ខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ ក្នុងកងយោធពលខេមរភូមិន្ទ ព្រមទាំងលើកសំណូមពរចាំបាច់មក **ក.ជ.ក** ។

**ប្រការ៤**: នាយកដ្ឋានអប់រំនៃអគ្គនាយកដ្ឋានយោធសេវា ជាលេខាធិការឱ្យក្រុមការងារដើម្បីកុមារនៃកងយោធពលខេមរភូមិន្ទ ។

**ប្រការ៥**: អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន មេបញ្ជាការកងឯកភាពពាក់ព័ន្ធ និងសមាសភាពក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**នាយឧត្តមសេនីយ៍.ទៀ~បាញ់**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ថ្នាក់ដឹកនាំក្រសួងការពារជាតិ

(ដើម្បីជូនជ្រាប)

- ដូចប្រការ១ និងប្រការ៥

(ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ